**ព្រះរាជាណាចក្រកម្ពុជា**

**ក្រុមប្រឹក្សាធម្មនុញ្ញ** **ជាតិ សាសនា ព្រះមហាក្សត្រ**

**សំណុំរឿង**

លេខ ០៥៤/០០៨/២០០២

ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០២

**សេចក្ដីសំរេច**

លេខ ០៤៩/០០៤/២០០២ កបធ.ច

ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានឃើញសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ស្ដីពីការបកស្រាយវាក្យខ័ណ្ឌទី ១ នៃមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- បានឃើញលិខិតប្រធានព្រឹទ្ធសភាស្ដីទីលេខ ១៥២ / ០៩០២ / ពស /នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី ២ និងទី ៥ នៃរដ្ឋធម្មនុញ្ញ ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្ដីទីបានសុំក្នុងលិខិតលេខ ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្ដីថា " បើព្រឹទ្ធសភា...ពុំបានឱ្យយោបល់សោះ " ហើយនិងកថាខ័ណ្ឌទី ៥ ដែលមានសេចក្ដីថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ

រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ " ។

- យល់ឃើញថា សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងការបកស្រាយរដ្ឋធម្មនុញ្ញមានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និងក្នុងមាត្រា១៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

តាមមាត្រា ១៤១ ថ្មី ក្នុងចំណោមឥស្សរជនដែលអាចលើកសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញគឺមានប្រធានព្រឹទ្ធសភាផងដែរ ។

ដូច្នេះ យោងតាមមាត្រា ១៣៦ ថ្មី និង ១៤១ ថ្មី នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពិនិត្យសំណើសុំបកស្រាយមាត្រា១១៣ថ្មីកថាខ័ណ្ឌទី២ និងទី៥ របស់ប្រធានព្រឹទ្ធសភាស្តីទីខាងលើនេះបាន ។

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីសុំឱ្យបកស្រាយជាដំបូង កថាខ័ណ្ឌទី ២នៃមាត្រា ១១៣ ថ្មី ត្រង់ពាក្យថា "បើព្រឹទ្ធសភា...ពុំបានឱ្យយោបល់សោះ " ។

តាមបទប្បញ្ញត្តិដែលមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រា ១១៣ថ្មី ព្រឹទ្ធសភាត្រូវពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្នុងករណីធម្មតា ប៉ុន្តែបើជាការប្រញាប់ គឺត្រឹមតែ ០៥ ថ្ងៃប៉ុណ្ណោះ ។ ដូច្នេះក្នុងករណីធម្មតា ផុតរយៈពេលមួយខែ គិតពីថ្ងៃដែល "រដ្ឋសភាបានដាក់ឱ្យពិនិត្យ"បើព្រឹទ្ធសភានៅស្ងៀមស្ងាត់ឥតធ្វើអ្វី ឬឥតឆ្លើយអ្វីសោះទៅរដ្ឋសភាវិញនោះ គឺបានន័យថា " ព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ " ។ ប៉ុន្តែពាក្យថា " ព្រឹទ្ធសភា " គឺមានន័យថា ត្រូវមានការប្រជុំពេញអង្គរបស់ព្រឹទ្ធសភាដើម្បីសំរេចថា "មិនឱ្យយោបល់ " ។

បញ្ហាដែលស្មុគស្មាញ គឺនៅត្រង់រដ្ឋសភាសុំឱ្យព្រឹទ្ធសភាពិនិត្យជា" ការប្រញាប់ " ។ ក្នុងករណីនេះ បើព្រឹទ្ធសភានៅស្ងៀមមិនឆ្លើយតបទៅវិញហួសពី ៥ ថ្ងៃ តើរដ្ឋសភាអាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបានឬទេ ?

យោងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦ /០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ និងដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាដែរ ព្រឹទ្ធសភាមានអំណាចសំរេចខ្លួនឯងថា "យល់ព្រម ឬ មិនយល់ព្រមទុកជាការប្រញាប់ " ។ ប៉ុន្តែបើព្រឹទ្ធសភាមិនបានសំរេចអ្វីសោះ ហើយនៅស្ងាត់ស្ងៀម លើសពី ៥ ថ្ងៃ នោះ ត្រូវចាត់ទុកថា ព្រឹទ្ធសភាទទួលយល់ព្រមថា ជាការប្រញាប់ ហើយរដ្ឋសភាអាចយកច្បាប់នោះទៅប្រកាសឱ្យប្រើក្នុងរយៈពេល ៥ ថ្ងៃបាន ។ បើព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គបានសំរេចថា " ជាការប្រញាប់" តាមសំណើសុំរបស់រដ្ឋសភា ហើយក៏បានធ្វើការពិភាក្សាទៅ ស្រាប់តែមានការរាំងស្ទះដោយថាហេតុបណ្តាលឱ្យហួសរយៈពេល ៥ ថ្ងៃទៅនោះ រដ្ឋសភាក្នុងករណីនេះ អាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបាន ដោយមិនចាំបាច់រង់ចាំការអនុម័តរបស់ព្រឹទ្ធសភាឡើយ ។

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីបានសុំជាបន្ទាប់មកទៀតឱ្យបកស្រាយកថាខ័ណ្ឌទី ៥ នៃមាត្រា ១១៣ ថ្មី ដែលមានសេចក្តីថា "បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភា ត្រូវបន្ថែមឱ្យស្មើគ្នាដែរ" ។

កថាខ័ណ្ឌទី ៥ នេះទាក់ទងនឹងរយៈពេលនៃ "ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា" ដែលមានចែងក្នុងកថាខ័ណ្ឌទី ៤ នៃមាត្រា ១១៣ ថ្មី ។

ក្នុងករណីព្រឹទ្ធសភាមិនឯកភាពតាមការអនុម័តដំបូងរបស់រដ្ឋសភា ព្រឹទ្ធសភាបង្វិលទៅរដ្ឋសភាជាលើកទី១ ស្នើសុំកែប្រែ ។ រដ្ឋសភាបានទទួលហើយ ប៉ុន្តែមិនឯកភាពទាំងស្រុង ឬដោយអន្លើ នឹងសំណើកែប្រែរបស់ព្រឹទ្ធសភា ក៏បង្វិលមកព្រឹទ្ធសភាវិញសុំឱ្យពិចារណាជាថ្មី ។ ព្រឹទ្ធសភាពិចារណាជាថ្មីហើយ ក៏បង្វិលទៅរដ្ឋសភាវិញ ដោយបញ្ជាក់យោបល់របស់ខ្លួនម្តងទៀត ។ បើរដ្ឋសភាមិនទាន់ឯកភាពតាមព្រឹទ្ធសភា ការបង្វិលទៅបង្វិលមកអាចបន្តទៅទៀតបាន ជាធម្មតាក្នុងរយៈពេលមួយខែសំរាប់ពិនិត្យច្បាប់ផ្សេង ១ ក្រៅពីច្បាប់ថវិកាជាតិ និងហិរញ្ញវត្ថុ ដែលត្រូវកំរិតត្រឹម ១០ ថ្ងៃ ។ បើជាការប្រញាប់ រយៈពេលនេះមកនៅត្រឹម ២ ថ្ងៃតែប៉ុណ្ណោះ ។ រយៈពេលនៃការបង្វិលនេះត្រូវគិតពីថ្ងៃបង្វិលលើកទី ១ របស់ព្រឹទ្ធសភា ។

ពាក្យថា "បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់" បានន័យថា ក្រោយបានទទួលការសុំឱ្យកែសំរួលសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះពីព្រឹទ្ធសភាទៅ រដ្ឋសភាមិនបានធ្វើអ្វីសោះរហូតផុត ១ ខែ ឬ ១០ ថ្ងៃ ឬ ២ថ្ងៃទៅតាមករណីនីមួយ១ ដូចបានរៀបរាប់ខាងលើ ។

ពាក្យថា "ពន្យារពេលដែលកំណត់ទុក" បានន័យថា រដ្ឋសភាបានធ្វើការប្រជុំពេញអង្គសំរេចពន្យារពេលពិនិត្យឱ្យលើសពី ១ ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ ទៅតាមករណីនីមួយ១នោះ ។

ពាក្យថា "*រយៈពេលជាគោលការណ៍* សំរាប់រដ្ឋសភា និងព្រឹទ្ធសភា" នោះ គឺរយៈពេល ១ ខែ ឬ ១០ថ្ងៃ ឬ ២ ថ្ងៃ នេះហើយ ។

ពេលវេលាដែលលើសពីរដ្ឋធម្មនុញ្ញកំណត់ ដោយសារការទុក ឬការសំរេចពន្យាររបស់រដ្ឋសភានេះ ត្រូវបន្ថែមឱ្យព្រឹទ្ធសភា ឱ្យបានស្មើគ្នានឹងរដ្ឋសភាដែរ ។ ក្នុងការអនុវត្តន៍ជាក់ស្តែង ដើម្បីឱ្យបានស្មើគ្នាកើត គេត្រូវរាប់ចំនួនថ្ងៃដែលរដ្ឋសភាបានប្រើប្រាស់ ក្នុងរយៈពេលទាំងនោះ ដើម្បីឱ្យដឹងច្បាស់ សំរាប់គិតចំនួនថ្ងៃដែលព្រឹទ្ធសភាត្រូវមានស្មើគ្នាដែរ ។

ដូច្នេះក្នុង "*រយៈពេលជាគោលការណ៍ ១ ខែ*" រដ្ឋសភាមានសិទ្ធិប្រើប្រាស់ ១៥ ថ្ងៃ ចំណែកឯព្រឹទ្ធសភា ក៏១៥ ថ្ងៃ ដូចគ្នាដែរ ។ បើរដ្ឋសភាប្រើពេលលើសថែម ឧបមាថា ៣ ថ្ងៃ ខាងព្រឹទ្ធសភាក៏ត្រូវមានសិទ្ធិបន្ថែម ៣ ថ្ងៃទៀត ដូច ១ គ្នា ។

របៀបគិតនេះ ត្រូវអនុវត្តដូចគ្នាចំពោះ "*រយៈពេលជាគោលការណ៍ ១០ ថ្ងៃ*" និង "*រយៈពេលជាគោលការណ៍ ២ ថ្ងៃ*" ទៅតាមករណីជាយថាហេតុ ។

ជារួមគេត្រូវចែក " *រយៈពេលជាគោលការណ៍* " នីមួយៗជាពីរស្មើគ្នា គឺថាបើ " *១០ ថ្ងៃ* " គឺ ៥ ថ្ងៃសំរាប់រដ្ឋសភា ហើយនិង ៥ ថ្ងៃទៀតសំរាប់ព្រឹទ្ធសភា ។ បើ " *២ ថ្ងៃ* " គឺ " *១ ថ្ងៃ* " សំរាប់រដ្ឋសភា និង " *១ ថ្ងៃ* " ទៀតសំរាប់ព្រឹទ្ធសភា ។ ហើយបើរដ្ឋសភាបន្ថែមលើសប៉ុន្មានថ្ងៃ ព្រឹទ្ធសភាក៏មានសិទ្ធិបន្ថែមចំនួនថ្ងៃលើសឱ្យស្មើគ្នានឹងរដ្ឋសភាដូចគ្នា ។

គួរកត់សំគាល់ម្យ៉ាងទៀតថា " *រយៈពេលជាគោលការណ៍* " ទាំងអស់នេះ សុទ្ធតែជា " *រយៈពេលមិនកត់* " ដែលគេត្រូវអនុវត្តតាមវិធានដែលមានចែងក្នុងសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ។

**សំរេច**

**មាត្រា ១ :** មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ត្រង់ពាក្យថា " បើព្រឹទ្ធសភា ... ពុំបានឱ្យយោបល់សោះ " និងកថាខ័ណ្ឌទី ៥ ត្រូវបកស្រាយ ដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២ :** សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។៚

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

បិន ឈិន